### ការបង្កើតគណៈកម្មការតាមដាន និង ត្រួតពិនិត្យ អាគារស្នាក់ ទីស្តីការគណៈរដ្ឋមន្ត្រី

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការមួយឈ្មោះថា " គណៈកម្មការតាមដាន និង ត្រួតពិនិត្យអាគារស្រុតទីស្តីការគណៈរដ្ឋមន្ត្រី " ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១_ឯកឧត្តម **ម៉ម សុផាណា** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ | ប្រធាន |
| ២_ឯកឧត្តម **ម៉ុន អ៊ុយ** | សហអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣_ឯកឧត្តម **អ៊ូ គីមសន** | សហអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤_លោក **អ៊ុត ឈន** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច | សមាជិក |
| ៥_លោក **គួច គី** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញកិច្ច | សមាជិក |

៦_លោកតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្នែកនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក

**ប្រការ ២** : គណៈកម្មការនេះមានសិទ្ធិ និង ភារកិច្ច ÷

- សិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យការស្រុតនៃអាគារ ទីស្តីការគណៈរដ្ឋមន្ត្រី
- កោះអញ្ជើញអ្នកឯកទេសតាមក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិគ្រោះពិភាក្សាជាមួយឯកឧត្តម ទេសរដ្ឋមន្ត្រីប្រធាន គណៈកម្មាធិការជាតិរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- អញ្ជើញអ្នកឯកទេស បរទេសផ្នែកអាគារស្រុត ដើម្បីជួយសិក្សាស្រាវជ្រាវបន្ថែម
- ធ្វើរបាយការណ៍ ស្តីពីលទ្ធផលក្រោយការសិក្សាស្រាវជ្រាវរួច និងលើកវិធានការជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**ប្រការ ៣** : •គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
•រាល់ការចំណាយជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឬទ្ធិ** | **ហ៊ុន សែន** |

* * *

# II - អាវខារបណ្តាក្រសួង

## ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ២៧ ឧក.ប្រក

**ប្រការ ១ :** អនុញ្ញាតអោយលោក **ឈី ម៉ុនីន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២២៤៧១ ភព ចុះថ្ងៃទី ២៦-៦-៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧២៧ អឺ១ ផ្លូវលេខ ៩៣ក្រុមទី ១៦ សង្កាត់បឹងកេងកងទី ៣ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការរោងជាងផលិត តុ ទូ កៅអី នៅក្នុងទីតាំង ផ្ទះលេខ ៧២៧ ផ្លូវលេខ ៩៣ ក្រុមទី ១៦ សង្កាត់បឹងកេងកង ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ ២ :** លោក **ឈី ម៉ុនីន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្មអាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល និង គោរពរាល់ច្បាប់បញ្ញត្តិ ដែលមានជាធរមាន ។

**ប្រការ ៤ :** រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ តុ ទូ កៅអី ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺ ឈើដែលមានលក្ខណៈស្របច្បាប់ ។

**ប្រការ ៥ :** ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ផ្ញើជូនមកក្រសួង តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ អំពីសកម្មភាពផលិតកម្មរបស់រោងជាង ។

**ប្រការ ៦ :** ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោង ជាងត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្ម របស់ខ្លួនឡើងវិញ ។

ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៨៦

## ប្រកាសលេខ ២៨ ឧក.ប្រក

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន វិញត្រូបអភិវឌ្ឍន៍ និង វិនិយោគ តំណាងដោយលោក **ទិញ ម៉ិ** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា អាស័យដ្ឋាន ផ្ទះលេខ ២០អី ផ្លូវលេខ ៥៧ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៥៨២៧ ចុះថ្ងៃទី ០១-១២-៩១ បង្កើត « រោងចក្រផលិតចារីសំរាប់នាំចេញក្នុងកំរិត ៨០% » ដែលមានឈ្មោះ « រោងចក្រចារីប្រេស៊ីដង់ »មានទីតាំងនៅ ឃុំកាកាប ស្រុកដង្កោ រាជធានីភ្នំពេញ។

**ប្រការ ២ :** ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់នឹងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រចារីដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៣ :** ការសាងសង់ការដំឡើងខ្សែចង្វាក់ផលិតកម្ម និង ការរៀបចំរចនាសម្ព័ន្ធផ្សេង ៗ របស់រោងចក្រត្រូវធ្វើអោយសំរេចជាស្ថាពរក្នុងរយៈពេល ០៦ ខែ ដោយ គិតរាប់បញ្ចូលទាំងរយៈពេលសាកល្បងដំណើរការផង ។

**ប្រការ ៤ :** សាម៉ីក្រុមហ៊ុនត្រូវជូនដំណឹងជាមុនក្នុងរយៈពេល១៥ ថ្ងៃយ៉ាងតិចដល់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីកាលបរិច្ឆេទនៃការផ្តើមដំណើរការជាផ្លូវការរបស់រោងចក្រ និង ត្រូវធ្វើរបាយការណ៍ជូនក្រសួងជារៀងរាល់ខែ នូវការសាងសង់ និង ស្ថានភាពផលិតកម្ម–អាជីវកម្ម របស់រោងចក្រ ។

**ប្រការ ៥ :** ក្នុងកិច្ចដំណើរការរោងចក្រ សាម៉ីក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពច្បាប់ និង បទបញ្ញត្តិទាំងឡាយដែលមានជាធរមាន ។

**ប្រការ ៦** : រោងចក្រត្រូវបានអនុញ្ញាតអោយ ផលិតថារី ស្របតាមតែសញ្ញាសំគាល់ ដែលដឹកល់ ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៧** : ក្នុងករណីប្រព្រឹត្តិល្មើសនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ : ២៩ ឧក.ប្រក

**ប្រការ ១** : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ជិន គីមស្រៀន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៣៣៨២ ប.ប ចុះថ្ងៃទី ០៩–១០–៨៦ ជាប្រធាន អាស័យ ដ្ឋានបច្ចុប្បន្ន ភូមិប្រាបក្រសាំង សង្កាត់វត្តគរ ទីរួមខេត្តបាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការផលិតកម្ម ដោយម៉ាស៊ីនកំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២** : លោក ជិន គីមស្រៀន ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្មលើ ទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបាន យ៉ាងតិចបំផុត ៦៥ ភាគរយ ។

**ប្រការ ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង ករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ : ៣០ ឧក.ប្រក

**ប្រការ ១** : អនុញ្ញាតអោយលោក **ខុន ហ៊ត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៩២៨៤ ភ.ព ចុះថ្ងៃទី ១២-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ០៥ ផ្លូវលេខ ១៥០ ក្រុមទី ៣៧ សង្កាត់ផ្សារ ដេប៉ូទី ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិត ម្សៅឆា « **ហុខ ហួត** » នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២** : លោក ខុន ហ៊ត ត្រូវបានអនុញ្ញាតអោយផលិត នូវមុខផលិតផលម្សៅឆា សញ្ញា « រូបក្តាន់ » ,« រូបរទេះភ្លើង » ,« រូបសេក » និង « រូបផ្ទៃទទឹម » ស្របតាមគំរូ សញ្ញាសំគាល់ដែលបានដំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ : ៣១ ឧក.ប្រក

**ប្រការ ១** : អនុញ្ញាតអោយសហគ្រាសផលិតគ្រឿងសង្ហារឹម « YALIHUNG International Investment & Development Group » ដែលមានលោក **ឡាយ ឆោវម្សៀន** ជនជាតិចិន សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៧៨៥៨៥ ភ.ព ចុះថ្ងៃទី ២០-៨-៩៤ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នផ្ទះ

លេខ ៧៨៩ ផ្លូវលេខ ៩៣ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការផលិតកម្មនៅក្នុងទីតាំង ព្រំប្រទល់ ភូមិព្រៃរការ ឃុំឆក់ឈើនាង និង ភូមិ ចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ។

**ប្រការ ២** : លោក **ឡាយ ឆេងឡៃន** ត្រូវរៀបចំសហគ្រាសរបស់ខ្លួនអោយស្រេចជាស្ថាពរ ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។

**ប្រការ ៣** : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

**ប្រការ ៤** : សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ សាឡុង តុ ទូ កៅអីឈើការ៉ូ នីវ ឈើពិដាន ទ្វារ បង្អួច គ្រោងទ្វារ បង្អួច ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្មគឺ ឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីសហគ្រាសត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

**ប្រការ ៥** : ម្ចាស់សហគ្រាសត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការជាផ្លូវការ និង ធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់សហគ្រាស ។

**ប្រការ ៦** : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់សហគ្រាសត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួន ឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ : ៣២ ឧក.ប្រក

**ប្រការ ១** : អនុញ្ញាតអោយលោក **ស៊ុន សន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៥៨៨៥ក.ព ចុះថ្ងៃទី ២៩-០១-៩៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ២៨ ស្ទួន ផ្លូវលេខ ៤៣២ សង្កាត់ទួលទំពូង ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះនៅក្នុងទីតាំង ភូមិ ឡ ឃុំ កាហែង ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ ។

**ប្រការ ២** : លោក **ស៊ុន សន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

**ប្រការ ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ : ៣៣ ឧក.ប្រក

**ប្រការ ១** : អនុញ្ញាតអោយអ្នកស្រី **ចេង សុគា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ២៥៨៣៣៩ ភ.ព ចុះថ្ងៃទី ១៩-៨-៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៦ បេអឺ០ ផ្លូវលេខ ៣១៨ ក្រុមទី ១៩ ភូមិ ៣ សង្កាត់ទួលស្វាយព្រៃទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរ ការសិប្បកម្មផលិតខ្សែក្រអូប សញ្ញា «I.Q» នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២ :** អ្នកស្រី **ចេង សុគា** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលកន្ទេល ក្រអូបសញ្ញា « I.Q » ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង ករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៨៦

## ប្រកាសលេខ : ៣៤ ឧក.ប្រក

**ប្រការ ១ :** អនុញ្ញាតអោយលោក **ទី វណ្ណា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់ អត្តសញ្ញាណប័ណ្ណលេខ ៣៣៨៤៧២ ក.ណចុះថ្ងៃទី១០-៧-៩១ អាស័យដ្ឋាន បច្ចុប្បន្ន ភូមិម្ល៉ឹន ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល បើកដំណើរ ការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាព ប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវ ដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

## ប្រកាសលេខ ៣៥ ឧក.ប្រក

**ប្រការ ១** : អនុញ្ញាតអោយអ្នកស្រី **ហម សុវណ្ណា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ១៤៧៣៨១ ភ.ព ចុះថ្ងៃទី០៦-៩-១៩៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៣៦ អឺ០ សង្កាត់ ទួលទំពូងទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង នៅក្នុងទីតាំង ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**ប្រការ ២** : ប្រកាសនេះមានតំលៃក្នុងរយៈបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹង ត្រូវ ដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

## ប្រកាសលេខ : ៣៦ ឧក.ប្រក

**ប្រការ ១** : អនុញ្ញាតអោយលោក **ចាន់ សេខ** ម្ចាស់សិប្បកម្មស្ករស កាន់អត្តសញ្ញាណប័ណ្ណ លេខ១០៧២២៧ភ.ព ចុះថ្ងៃទី ០៧–៣–១៩៩២ ដែលមានទីតាំងនៅផ្ទះលេខ ៥៤៦ ហ្សិត ផ្លូវ លេខ ០២ ភូមិ តាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ប្តូរទីតាំងផលិតកម្មចាស់ទៅកាន់ទីតាំងថ្មី ។

**ប្រការ ២** : ទទួលស្គាល់ទីតាំងថ្មីនៃសិប្បកម្មផលិតស្ករស របស់លោក **ចាន់ សេខ** ដែលមានទីតាំងលេខ៩ ថ ក្រុមទី ១៨ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានី ភ្នំពេញ ។

ប្រការ ៣ : ប្រកាសលេខ ២៥៤ ផក.ប្រក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៣ របស់ក្រសួងឧស្សាហកម្ម ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណី ប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

## ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០២៦/៩៦ ពម.ប្រក**

**អនុញ្ញាតឱ្យលោក ឡាយ ទីនធីវ**

**នាំចូលសារពត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយ ប្រើតាមព្រះរាជក្រម លេខ ន.ស.រ.ក.ម ០៨៩៥–០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ។

– បានឃើញសំណើនាំចូលកាសែត និង ទស្សនាវដ្តី ភាសាចិនពីប្រទេសតៃវ៉ាន់ មកព្រះ រាជាណាចក្រកម្ពុជា របស់លោក ឡាយ ទីនធិ៊ុវ ប្រធានក្រុមហ៊ុន «អេវ៉ាត្រេឌីង និងទេសចរណ៍» ចុះថ្ងៃទី ០៩ មករា ១៩៩៦ ។

## សម្រេច

**ប្រការ ១** : អនុញ្ញាតអោយលោក **ឡាយ ទីនធិ៊ុវ** នាំចូលនូវសារពត៌មានឈ្មោះ ÷

១–កាសែត « ជុងគ័រសឺប៉ាវ » ចំនួន ១០០ ច្បាប់
២–កាសែត « លៀនហឺប៉ាវ » ចំនួន ១០០ ច្បាប់
៣–កាសែត « ជឺយ៉ូវប៉ាវ » ចំនួន ១០០ ច្បាប់
៤–កាសែត « កុងសាំងសឺប៉ាវ » ចំនួន ១០០ ច្បាប់
៥–ទស្សនាវដ្តី « សឺប៉ាវចូវខាន់ » ចំនួន ១០០ ច្បាប់

ជាភាសាចិនចេញពីប្រទេសតៃវ៉ាន់ ចូលមកព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រុមហ៊ុន « EVA TRADING និង TOURISM CO . LTD. » ដែលមានទីស្នាក់ការ[illegible]នៅផ្ទះលេខ ៧២ E₀ ផ្លូវលេខ ១២៦ [illegible] ១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

**ប្រការ ២** : លោក **ឡាយ ទីនធិ៊ុវ** ត្រូវប្រគល់កាសែត និង ទស្សនាវដ្តី[illegible] ម្តងៗ ចំនួន [illegible]ច្បាប់ជៀងរាល់លេខ ដែលនាំចូលមកតំកល់ទុក ជាឯកសារ នៅក្រសួងពត៌មាន ។

**ប្រការ ៣** : ការនាំចូលនូវសារពត៌មាន ដែលមានអត្ថបទ និង រូបភាពអាសអាភាសត្រូវហាមឃាត់ ។ រាល់សកម្មភាពចែកផ្សាយ ត្រូវគោរពតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**ខៀវ កាញារីទ្ធ**

រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ០២៧/៩៦ ពម.ប្រក**

**អនុញ្ញាតឱ្យព្រឹត្តិប័ត្រឈ្មោះ « ភ្លេចដំណឹង »**

**ចេញផ្សាយជាភាសាខ្មែរ និង អង់គ្លេស**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់ស្តីពីរបបសារពតិមាន នៃព្រះរាជាណាចក្រកម្ពុជាដែល ប្រកាសអោយប្រើ តាមព្រះរាជក្រមលេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ។
- បានឃើញសំណើសុំបោះពុម្ពព្រឹត្តិប័ត្រឈ្មោះ «ភ្លេចដំណឹង»«FORGET NEWS» របស់លោក ឡុង ផា ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយព្រឹត្តិប័ត្រឈ្មោះ « ភ្លេចកំណើង » « FORGET NEWS » ចេញផ្សាយជាភាសាខ្មែរ និង អង់គ្លេស ដោយមានលោក **ឡុង ផា** ជាចាង ហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ៨២ ក្រុមទី ៥ សង្កាត់ស្ទឹងមានជ័យ ក្រុង ភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុង អត្តសញ្ញាណ ប័ណ្ណនៃសារពតិមានរបស់ខ្លួនត្រូវជូនដំណឹងជាមុន១០ ថ្ងៃមកក្រសួងពតិមាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

**ប្រការ ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទ ត្រូវអនុវត្តអោយបានសមស្រប តាមទំនៀមទំលាប់ ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ព្រឹត្តិប័ត្រចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពតិមាន ។

**ប្រការ ៣** : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើសាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៤** : លោក **ឡុង ផា** ជាចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

**ប្រការ ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ : ០២៨/៩៦ ពម.ប្រក

## អនុញ្ញាតឱ្យព្រឹត្តិប័ត្រឈ្មោះ «ព្រឹត្តិប័ត្រស្រាវជ្រាវអភិវឌ្ឍន៍សង្គម » បោះពុម្ពចែកផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស អោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ។
- បានឃើញសំណើបោះពុម្ពផ្សាយព្រឹត្តិប័ត្រឈ្មោះ « ព្រឹត្តិប័ត្រស្រាវជ្រាវអភិវឌ្ឍន៍សង្គម »របស់លោក ប៊ុក ថន ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៥

**សម្រេច** :

**ប្រការ ១** : អនុញ្ញាតអោយព្រឹត្តិប័ត្រឈ្មោះ «ព្រឹត្តិប័ត្រស្រាវជ្រាវអភិវឌ្ឍន៍សង្គម» បោះពុម្ពចែកផ្សាយដោយមានលោក **ម៉ុក ឆន** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ១៩ ផ្លូវ ១៦៣ សង្កាត់វាលវង់ ខ័ណ្ឌ ៧ មករា ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណប័ណ្ណ នៃព្រឹត្តិប័ត្ររបស់ខ្លួនត្រូវជូនដំណឹងជាមុន ១០ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេច ជាថ្មី ។

**ប្រការ ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទអនុវត្តន៍អោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ព្រឹត្តិប័ត្រចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

**ប្រការ ៣** : ក្នុងករណីប្រព្រឹត្តិល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើសាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៤** : លោក **ម៉ុក ឆន** ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មានត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

* * *

# ៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួង កសិកម្ម
# រុក្ខាប្រមាញ់ និង នេសាទ

## សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៦

## សេចក្តីសំរេច ០៣៨ សសរ.កសក
## ស្តីពីការបង្កើតគណៈកម្មការអនុវត្តគំរោងកម្មវិធី KRII
## ដែលជាជំនួយរបស់រាជរដ្ឋាភិបាលជប៉ុន

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី [illegible] សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
– បានឃើញកិច្ចព្រមព្រៀង ស្តីពីជំនួយរបស់ជប៉ុន ដើម្បីគំរោងការបង្កើនផលិតផលស្បៀងនៅកម្ពុជា ដែលបានចុះហត្ថលេខារវាង ឯកឧត្តម ហោ ណាំហុង រដ្ឋមន្ត្រីការបរទេស សមាជិកក្រុមប្រឹក្សា ជាតិជាន់ខ្ពស់កម្ពុជា និង ឯកឧត្តម យ៉ូស៊ីអាគីហាតា ប្រធានបេសកកម្ម JICA ជប៉ុន កាលពីថ្ងៃទី១៧ ខែ មិថុនា ១៩៩២
– យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការអនុវត្តគំរោង KRII មួយដែលមានសមាសភាពដូចខាងក្រោម :

១–លោក **ឡៅ នី** ប្រធាននាយកដ្ឋានផែនការ–ស្ថិតិ ប្រធាន

២–លោក **ឈួន គីមឆោ** ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ អនុប្រធាន

៣–លោក **ជ័យ សារឧត្ត** ប្រធានក្រុមហ៊ុនសំភារៈកសិកម្ម សមាជិក

៤–លោក **ម៉ារស់ សុខ** អនុប្រធាននាយកដ្ឋានកៀគ្រសាស្ត្រ សមាជិក

៥–លោក **សាន ទន្តុធី** មន្ត្រីផែនការស្ថិតិ សមាជិករាយការណ៍

៦–លោក **គីរុន សុំប៊ួន** មន្ត្រីផែនការស្ថិតិ សមាជិក រាយការណ៍

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ចធ្វើការបែងចែកតាមដាន និង ត្រួតពិនិត្យការប្រើប្រាស់សំភារៈកសិកម្ម នៃគំរោង KRII ធ្វើការវាយតំលៃ និងធ្វើរបាយការណ៍លើ នៃការអនុវត្តន៍គំរោងនេះជាប្រចាំ ។

**ប្រការ ៣** : អគ្គនាយក[illegible] ប្រធាននាយកដ្ឋាន[illegible] ប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកៀគ្រសាស្ត្រ ប្រធានក្រុមហ៊ុនសំភារៈកសិកម្ម និង សាមីជនដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តី សំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**ឈា សុខ**

* * *

# ៤ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ០៩១ ប្រ.កបស្ថ
## ស្ដីពីការទទួលក្របខ័ណ្ឌមន្ត្រីរាជការ

* * *

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល

– បានឃើញច្បាប់ស្ដីពីការរៀបចំនឹងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសដោយព្រះរាជក្រម លេខ ០២ ន.ស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– យោងប្រកាសលេខ ០២១ ប្រក. ចុះថ្ងៃទី ០៦–០១–១៩៩៦ របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១** : ទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការចំនួន ០៦ កន្លែង អោយទៅបំរើការងារនៅមន្ទីរបរិស្ថានខេត្ត សៀមរាប ដូចមានរាយនាមខាងក្រោម ÷

| | |
|---|---|
| ១–លោក **នួន វិចិត្រ** | ៤–លោក **នួច សារឿន** |
| ២–លោក **ឈឿន ម៉ៅ** | ៥–លោក **ម៉ាន់ ខ្មៅ** |
| ៣–លោក **សាត សេដ្ឋា** | ៦–លោក **ផ្លាន់ ប៊ុរិន** |

**ប្រការ ២** : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាម៉ីជនមន្ទីរបរិស្ថាន ខេត្តសៀមរាបបានផ្ដត់ផ្គង់ បន្ទាប់ពីមានវិញ្ញាបនប័ត្រផ្ដាច់ប្រាក់ពីអង្គភាពដើម ។

**ប្រការ ៣** : ខុទ្ទកាល័យ អគ្គនាយក មន្ទីរគ្រប់គ្រងបរិស្ថានខេត្តសៀមរាប អង្គភាពពាក់ព័ន្ធ នឹង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**បណ្ឌិត ម៉ុក ម៉ារ៉េត**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ០៩២ ប្រ.កបស្ថ

## ស្តីពីការទទួលក្របខ័ណ្ឌមន្ត្រីរាជការ

* * *

### រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនឹងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ ន.ស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងប្រកាសលេខ ០២២ ប្រក. ចុះថ្ងៃទី ០៦-០១-១៩៩៦ របស់ក្រសួងមហាផ្ទៃ

### សម្រេច

**ប្រការ ១** : ទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការចំនួន ១១ កន្លែង អោយទៅបំរើការងារនៅមន្ទីរបរិស្ថានខេត្ត ព្រះវិហារ ដូចមានរាយនាមខាងក្រោម :

១-លោក **ហុង ឆឿន** ៧-លោក **យឹម ឧុន្នី**

៤–លោក ចាន់ ប៊ុនថា ១០–លោក ឆែត ឡេង

៥–លោក ឡុង សុនលី ១១–លោក សោម រិទ្ធ

៦–លោក ហុង ហៀង

**ប្រការ ២** : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីជន មន្ទីរបរិស្ថានខេត្តព្រះវិហារបានទទួលផ្តល់ជូនបន្ទាប់ពីមានវិញ្ញាបនប័ត្រផ្តាច់ប្រាក់ពីអង្គភាពដើម ។

**ប្រការ ៣** : ខុទ្ទកាល័យ អគ្គនាយក មន្ទីរបរិស្ថានខេត្តព្រះវិហារ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ម៉ុក ម៉ារ៉េត**

**ប្រកាសលេខ ០៩៤ ប្រ.ក.បស្ថ**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

* * *

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ធារដ៏ម**

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ ន.ស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- យោងសំណើរបស់មន្ទីរបរិស្ថានខេត្តព្រះវិហារលេខ ២៨ បស្ថ.ពហ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៥

- ពិនិត្យលើការចាំបាច់របស់មន្ទីរបរិស្ថានខេត្តព្រះវិហារ

**សម្រេច**

**ប្រការ ១** : តែងតាំងមន្ត្រីរាជការថ្នាក់ការិយាល័យចំណុះអោយមន្ទីរបរិស្ថានខេត្តព្រះវិហារ ដូចមានរាយឈ្មោះខាងក្រោម

- លោក **ហុង ធឿន** ជាប្រធានការិយាល័យអប់រំបរិស្ថានការពារធម្មជាតិ និង កិច្ចការច្បាប់

- លោក **ថ្លាង គឹមសុ** ជាប្រធានការិយាល័យ ផែនការបរិស្ថាន និងត្រួតត្រាការប្រតិបត្តិ

- លោក **ម៉េង សំផុន** ជាអនុប្រធានការិយាល័យផែនការបរិស្ថាន និងត្រួតត្រាការប្រតិបត្តិ

**ប្រការ ២** : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗត្រូវបានកែសំរួលតាមតួនាទី ភារកិច្ចថ្មីរបស់ខ្លួន ។

**ប្រការ ៣** : អគ្គនាយក ខុទ្ទកាល័យ មន្ទីរបរិស្ថានខេត្តព្រះវិហារ និងសាម៉ីខ្លួន ត្រូវទទួលបន្ទុកអនុវត្តន៍ ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**បណ្ឌិត មុក ម៉ារ៉េត**

* * *

# ៥ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ០០៥ បនប្រក

## អនុញ្ញាតឱ្យអង្គការ ASSEMBLIES OF GOD បន្តការ ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ៦ គ្រឿង

## រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥–៣–១៩៨៧ ស្តីពីប្រៃសណីយ៍និង ទូរគមនាគមន៍
- បានឃើញពាក្យស្នើសុំបន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF របស់ អង្គការ ASSEMBLIES OF GOD លេខ ០០៧២១០២ ចុះថ្ងៃទី០៤-០១-១៩៩៦
- ប្រកាសលេខ ១៦០ បទ ប្រកទអ ចុះថ្ងៃទី ១៣–១០–១៩៩៤
- សេចក្តីជូនដំណឹងលេខ ២៧៤៩ បទ ចុះថ្ងៃទី ០៥–១០–១៩៩៥

## សម្រេច

**ប្រការ ១** : អនុញ្ញាតអោយអង្គការ ASSEMBLIES OF GOD បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ០៦ គ្រឿង ។

**ប្រការ ២** : ប្រកាសលេខ ១៦០ បទ ប្រកទអ ចុះថ្ងៃទី ១៣–១០–១៩៩៤ ទុកជានិរាករណ៍ ។

**ប្រការ ៣** : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និង អង្គការ ASSEMBLIES OF GOD ត្រូវអនុវត្តតាមប្រកាសនេះ ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**សូ យុន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ០០៦ បទប្រក

## អនុញ្ញាតឱ្យអង្គការ WORDVISION បន្តការ

## ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ១៣ គ្រឿង

## រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង

## ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥-៣-១៩៨៧ ស្តីពីប្រៃសណីយ៍និង ទូរគមនាគមន៍
- បានឃើញពាក្យស្នើសុំបន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF របស់អង្គការWORLD VISION លេខ ០០៦២១០១ ចុះថ្ងៃទី ២២-១២-១៩៩៥
- ប្រកាសលេខ ០៦៣ បទ ប្រក.ប្រក ចុះថ្ងៃទី ២០-៦-១៩៩៤
- សេចក្តីជូនដំណឹងលេខ ២៧៤៩ បទ ចុះថ្ងៃទី ០៥-១០-១៩៩៥

## សម្រេច

**ប្រការ ១** : អនុញ្ញាតអោយអង្គការ WORLD VISION បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ១៣ គ្រឿង ។

**ប្រការ ២** : ប្រកាសលេខ ០៦៣ បទ ប្រកប្រក្រ ចុះថ្ងៃទី ២០-០៦-១៩៩៤ ទុកជានិរាករណ៍ ។

**ប្រការ ៣** : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និង អង្គការ WORLD VISION ត្រូវអនុវត្តតាមប្រកាសនេះ ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

[illegible] ឃុន

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ០០៧ បទប្រក

## អនុញ្ញាតឱ្យអង្គការ WORLD CONCERN បន្តការ ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០២ គ្រឿង

## រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥–០៣–១៩៨៧ ស្តីពីប្រៃសណីយ៍និង ទូរគមនាគមន៍

– បានឃើញពាក្យស្នើសុំបណ្ណការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF របស់អង្គការ WORLD CONCERN ចុះថ្ងៃទី ១១–០១–១៩៩៦

– ប្រកាសលេខ ២៩ ប្រក តម បទក ចុះថ្ងៃទី ០៥–០៧–១៩៩៣

– ប្រកាសលេខ ០០៤ ប្រក.បទ ចុះថ្ងៃទី ១៣–០៤–១៩៩៣

– សេចក្តីជូនដំណឹងលេខ ២៧៤៩ មទ ចុះថ្ងៃទី ០៥–១០–១៩៩៥

**សម្រេច**

**ប្រការ ១** : អនុញ្ញាតអោយអង្គការ WORLD CONCERN ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០២ គ្រឿង ។

**ប្រការ ២** : ប្រកាសលេខ ០០៤ ប្រកបទ ចុះថ្ងៃទី ១៣–០៤–១៩៩៣ និងប្រកាសលេខ ២៩ ប្រក តម បទក ចុះថ្ងៃទី ០៥–០៧–១៩៩៣ ទុកជានិរាករណ៍ ។

**ប្រការ ៣** : នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និងអង្គការ WORLD CONCERN ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**សូ ឃុន**

# ៦ - ទីស្តីការក្រសួងធម្មការ និង សាសនា

## ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ១៦/៩៦ កធស.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ដែលប្រកាសអោយប្រើ តាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ដែលរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា
- បានឃើញលិខិតលេខ ០១ ណ.ស ចុះថ្ងៃទី ០២-០១-១៩៩៦ របស់មន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ
- អនុលោមទៅលើការចាំបាច់ និង សមត្ថភាពមន្ត្រីរាជការ

## សំរេច

**ប្រការ ១** : តែងតាំងលោក **ធ្លាក់ ហ៊ុត** ជានាយករងទី ២ ក្នុងមន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ។

**ប្រការ ២** : បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក **ធ្លាក់ ហ៊ុត** អាស្រ័យដោយមន្ទីរធម្មការ និង សាសនារាជធានីភ្នំពេញ ជាអ្នករៀបចំ និង ចាត់ចែង ។

**ប្រការ ៣** : មន្ទីរធម្មការ និង សាសនា មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុរាជធានីភ្នំពេញ និង លោក **ច្រាក់ ម៉ិត** សហការអនុវត្តន៍តាមប្រកាសនេះរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខានិងត្រា

**ហៀង វណ្ណារ័ត្ន**

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៩៣០ រៀល